**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ធនាគារជាតិ នៃ កម្ពុជា**

លេខ.៩១៤..០២៤..០៥៤ ប.ក.ព.ព័ត៌មាន

ថ្ងៃពុធ ១រោច ខែភទ្របទ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨
រាជធានីភ្នំពេញ ថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០២៤

# សេចក្តីប្រកាសព័ត៌មាន
## ស្តីពី
## វេទិកាបច្ចេកវិទ្យាហិរញ្ញវត្ថុនៅកម្ពុជាឆ្នាំ២០២៤ "CamTech Summit 2024"

នៅថ្ងៃពុធ ១ រោច ខែភទ្របទ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨ ត្រូវនឹងថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០២៤ លោកជំទាវបណ្ឌិត **ជា សិរី** ទេសាភិបាល ធនាគារជាតិនៃកម្ពុជា បានអញ្ជើញចូលរួមជាអធិបតី និងថ្លែងសុន្ទរកថាបើកក្នុងវេទិកាបច្ចេកវិទ្យាហិរញ្ញវត្ថុនៅកម្ពុជាឆ្នាំ២០២៤ (CamTech Summit 2024) ដែលរៀបចំឡើងដោយធនាគារជាតិនៃកម្ពុជា សហការជាមួយសមាគមសហព័ន្ធហិរញ្ញវត្ថុ និងបច្ចេកវិទ្យាកម្ពុជា នៅមណ្ឌលសិក្សាបច្ចេកទេសធនាគារ។ វេទិកានេះ ប្រព្រឹត្តទៅរយៈពេល ពីរថ្ងៃ គិតចាប់ពីថ្ងៃទី១៨ ដល់ថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០២៤ និងមានការអញ្ជើញចូលរួមពីតំណាងក្រសួង-ស្ថាប័នពាក់ព័ន្ធ គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ក្រុមហ៊ុនបច្ចេកវិទ្យាហិរញ្ញវត្ថុ និងធុរកិច្ចថ្មី បញ្ញត្តិករ និងវាគ្មិនកិត្តិយស សរុបប្រមាណ ៤៥០ រូប។

វេទិកាបច្ចេកវិទ្យាហិរញ្ញវត្ថុកម្ពុជាឆ្នាំ២០២៤ នេះរៀបចំឡើងក្នុងគោលបំណងផ្តល់ការគាំទ្រ និងជំរុញការអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុនៅកម្ពុជា តាមរយៈការតាំងបង្ហាញស្តង់ពិព័រណ៍ផ្សព្វផ្សាយផលិតផលបច្ចេកវិទ្យាហិរញ្ញវត្ថុប្រកបដោយនវានុវត្តន៍ ការចូលរួមសិក្ខាសាលា កិច្ចពិភាក្សា ការផ្លាស់ប្តូរយោបល់ ចំណេះដឹង និងបទពិសោធ ដោយឈរលើនិន្នាការថ្មីៗនៃការអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុនៅក្នុងប្រទេសកម្ពុជា ក្នុងតំបន់ និងសកល ដែលមានជាអាទិ៍ដូចជា បញ្ញាសិប្បនិម្មិត និងបច្ចេកវិទ្យាប្លុកឆេន និងតួនាទីរបស់គម្រោងថ្នាលច្រករបៀងតម្លាភាពហិរញ្ញវត្ថុ ដែលជាថ្នាលជួយលើកកម្ពស់ដល់សហគ្រាសធុនតូចនិងមធ្យមនៅកម្ពុជា ក្នុងការប្រកបអាជីវកម្មប្រកបដោយនវានុវត្តន៍ឆ្ពោះទៅរកសេដ្ឋកិច្ចឌីជីថល។ ទន្ទឹមនឹងនោះ វេទិកានេះនឹងលើកបង្ហាញពីបញ្ហាប្រឈម និងកាលានុវត្តភាពនៃប្រព័ន្ធអេកូឡូស៊ីបច្ចេកវិទ្យាហិរញ្ញវត្ថុកម្ពុជា ដើម្បីរួមចំណែកក្នុងការដោះស្រាយបញ្ហាប្រឈមផ្សេងៗ និងពន្លឿនការអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុនៅកម្ពុជា។

នេះជាសមិទ្ធផលរបស់ធនាគារជាតិនៃកម្ពុជា ក្នុងការអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងវិស័យធនាគារ ស្របតាមគោលនយោបាយអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុកម្ពុជា ២០២៣-២០២៨ ដែលបានដាក់ចេញដោយរាជរដ្ឋាភិបាល កាលពីឆ្នាំ២០២៣។

ទំនាក់ទំនង ៖
ផ្នែកទំនាក់ទំនង ធនាគារជាតិនៃកម្ពុជា
ទូរស័ព្ទ ៖ (៨៥៥) ២៣ ៩៩០ ១៩៦
អ៊ីម៉ែល ៖ nbccommunication@nbc.gov.kh
បណ្តាញសារព័ត៌មានផ្លូវការរបស់ធនាគារជាតិនៃកម្ពុជា៖
www.nbc.gov.kh, www.facebook.com/nationalbankofcambodiaofficial , www.twitter.com/nbccambodia ,
www.instagram.com/nationalbankofcambodia , www.linkedin.com/company/national-bank-of-cambodia ,
www.youtube.com/channel/UC3GoCm_QGSSLjXZXvbcATfA